# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈទន្តពេទ្យកម្ពុជា
ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ
លេខ០០២៧១/១៥.....កទជ

ភ្នំពេញថ្ងៃទី២០......ខែមេសា.........ឆ្នាំ២០១៥

# សេចក្ដីសម្រេច

## ស្ដីពី

# ការបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ត

## ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៣៩៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៣៥៦.អនក្រ.តត ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ
- បានឃើញសេចក្ដីសម្រេចលេខ ០០១៩/១៥ កទជ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ស្ដីពីបទបញ្ជាផ្ទៃក្នុងគណៈទន្តពេទ្យកម្ពុជា
- តាមតម្រូវការចាំបាច់

# សម្រេច

**ប្រការ ១.-**

ទន្តពេទ្យជាតិ និងទន្តពេទ្យបរទេសគ្រប់រូប ក្រោយពីទទួលបានការចុះឈ្មោះក្នុងបញ្ជីគណៈទន្តពេទ្យកម្ពុជា និងទទួលបានសិទ្ធិប្រកបវិជ្ជាជីវៈទន្តសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា តម្រូវឲ្យបំពេញការបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ត ចំនួន ២៥(ម្ភៃប្រាំ)ពិន្ទុក្នុង១ឆ្នាំ ដើម្បីបញ្ជាក់ពីការអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងរក្សាបានជាសមាជិកភាពរបស់គណៈទន្តពេទ្យកម្ពុជាបន្ត ។

**ប្រការ ២.~**

បែបបទនៃការកំណត់ពិន្ទុ ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តត្រូវបានកំណត់ដូចខាងក្រោមៈ

ក.ការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តជាការប្រជុំគ្លីនិក

-ទន្តពេទ្យចូលរួមម្តង: ១ពិន្ទុ

-ទន្តពេទ្យធ្វើបទបង្ហាញម្តង: ២ពិន្ទុ

ខ.ការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តជាសិក្ខាសាលា សន្និសីទជាតិ អន្តរជាតិ ដែលមានការយល់ព្រមនិងឯកភាពពីគណៈទន្តពេទ្យកម្ពុជា។

-ទន្តពេទ្យចូលរួមមួយថ្ងៃ: ៥(ប្រាំ)ពិន្ទុ

-ទន្តពេទ្យធ្វើបទបង្ហាញមួយម៉ោង: ៥(ប្រាំ)ពិន្ទុ

ប្រធានបទដដែលមួយម៉ោង: ២.៥(ពីរកន្លះ)ពិន្ទុ

គ.ការផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រដោយមានការយល់ព្រមនិងឯកភាពពីគណៈទន្តពេទ្យកម្ពុជា

-ទន្តពេទ្យផ្សព្វផ្សាយ: ៥(ប្រាំ)ពិន្ទុ

-ទន្តពេទ្យជំនួយការ: ២(ពីរ)ពិន្ទុ

ឃ.ទន្តពេទ្យសរសេរ ឬកែសម្រួលអត្ថបទគតិយុត្តិ ឬគោលនយោបាយសុខភាពៈ

-ទន្តពេទ្យសរសេរអត្ថបទ: ៥(ប្រាំ)ពិន្ទុ

-ទន្តពេទ្យចូលរួមសរសេរអត្ថបទ: ៣(បី)ពិន្ទុ

ង.ធ្វើបទបង្ហាញអត្ថបទវិទ្យាសាស្ត្រ

-ទន្តពេទ្យសម្របសម្រួល: ៥(ប្រាំ)ពិន្ទុ

-ទន្តពេទ្យគ្រប់គ្រងកម្មវិធី និងទន្តពេទ្យពាក់ព័ន្ធ: ២(ពីរ)ពិន្ទុ

ច.ការសរសេរអត្ថបទវិទ្យាសាស្ត្រ ៥០(ហាសិប)ទំព័រA4

-ទន្តពេទ្យសរសេរអត្ថបទ: ១០(ដប់)ពិន្ទុ

-ទន្តពេទ្យជំនួយការ: ៥(ប្រាំ)ពិន្ទុ

ឆ.ទន្តពេទ្យត្រួតពិនិត្យអត្ថបទ

-ប្រធាន: ៥(ប្រាំ)ពិន្ទុ

-ទន្តពេទ្យពាក់ព័ន្ធផ្សេងទៀត: ២(ពីរ)ពិន្ទុ

ជ.និក្ខេបបទ

-នាយកនិក្ខេបបទ: ៥(ប្រាំ)ពិន្ទុ

-ទន្តពេទ្យពាក់ព័ន្ធផ្សេងទៀត: ២(ពីរ)ពិន្ទុ

ឈ.ទន្តពេទ្យដឹកនាំកម្មសិក្សា

-មួយត្រីមាស: ៤(បួន)ពិន្ទុ

-មួយឆមាស: ៦(ប្រាំមួយ)ពិន្ទុ

**ប្រការ ៣.~**

ចំពោះទន្តពេទ្យ មិនធ្វើការងារគ្លីនិកសោះ (ដូចជាទន្តពេទ្យដែលធ្វើតែការងារបង្រៀន ការងារសុខភាពសាធារណៈ កម្មវិធីឬនយោបាយសុខាភិបាល ត្រូវធ្វើសិក្ខាសាលាដោយឡែកពាក់ពន្ធនិង

ការងារប្រចាំថ្ងៃ) តម្រូវឲ្យបំពេញការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ចំនួនត្រឹមតែ ១២,៥ (ដប់ពីរកន្លះ)ពិន្ទុ ក្នុង១(មួយ)ឆ្នាំ។

ប្រការ ៤.~

ការចេញវិញ្ញាបនប័ត្របញ្ជាក់សមាជិកភាពគណៈទន្តពេទ្យកម្ពុជាបន្ត ត្រូវគោរពតាមគោលការណ៍ដែលបានចែងខាងលើ។

**ប្រការ ៥.~**

អគ្គលេខាធិការគណៈទន្តពេទ្យជាតិ ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ រាជធានី ខេត្ត ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាព។

**ប្រការ ៦.~**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.~**

សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ช. ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**

**ប្រធាន**

**ឯកឧត្តម.សុខុម រិទ្ធីវុធ**

កន្លែងទទួល៖

-នាយកដ្ឋានធនធានមនុស្ស ក្រសួងសុខាភិបាល
-មន្ទីរសុខាភិបាលរាជធានី-ខេត្ត
-មហាវិទ្យាល័យទន្តវេទសាស្ត្រគ្រប់សាកលវិទ្យាល័យ
-ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ
-ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី-ខេត្ត
-ផ្សព្វផ្សាយ
-ឯកសារ-កាលប្បវត្តិ